*Kampuchean Action for Primary Education*

**អង្គការសកម្មភាពសំរាប់បឋមសិក្សានៅកម្ពុជា**

**ឯកសារយោង**

# ការប្រើប្រាស់ប្រអប់សង្គ្រោះបន្ទាន់នៅសាលារៀន

**( សេចក្តីព្រាង )**

**កំពង់ចាម , ខែ ៦ ២០០៣**

**ឧបត្ថម្ភគាំទ្រដោយអង្គការ យូនីសេហ្វ / ស៊ីដា**

# ការប្រើប្រាស់ប្រអប់សង្គ្រោះបន្ទាន់នៅសាលារៀន

## I. សេចក្តីផ្តើម :

ជាការពិតណាស់ គ្រោះថ្នាក់បន្តិចបន្តួចតែងតែកើតមានឡើងយ៉ាងងាយនៅក្នុងសាលា ហើយបើគ្រោះថ្នាក់នោះបង្កមានស្នាមរបួស ឬ ការឈឺចាប់ ហើយមិនព្យាបាលអោយបានសមស្របនោះ សិស្សអាចនឹងកើតជំងឺបានយ៉ាងងាយ ។ ហេតុដូច្នេះហើយ បានជាការប្រើប្រាស់ប្រអប់សង្គ្រោះបន្ទាន់មានសារៈសំខាន់ ។ ឯកសារនេះផ្តល់ជំនួយដល់នាយកសាលា , នាយករង ព្រមទាំងលោកគ្រូ-អ្នកគ្រូ ដើម្បីរៀបចំប្រអប់នេះទៅតាមសាលារៀន ។

## II. គោលបំណង :

សាលារៀន អាចផ្តល់ការព្យាបាលជាបន្ទាន់ដល់កុមារ ដែលមានជំងឺស្រាល ៗ ឬ មានគ្រោះថ្នាក់ ។

## III. ពេលវេលា :

ការប្រជុំជាមួយគ្រូទាំងអស់ ត្រូវចំណាយពេល កន្លះ ថ្ងៃ ។ បន្ទាប់ពីការប្រជុំនេះរួច និង មានការបំប៉នខ្លីរយៈពេល ១ ថ្ងៃ អំពីការប្រើប្រាស់ប្រអប់សង្គ្រោះបន្ទាន់ ។

## IV. សម្ភារ :

- ក្រដាសរ៉ាម A ៤
- ហ្វឺតក្តារខៀន
- ក្តារខៀន ស ។

## V. លំនាំបង្រៀន :

1. នាយកសាលា ត្រូវរៀបចំការប្រជុំជាមួយគ្រូទាំងអស់ នៅក្នុងសាលាដោយពន្យល់ថា សាលាបានទិញប្រអប់សង្គ្រោះបន្ទាន់ ដើម្បីព្យាបាលសិស្សនៅពេលដែលគេមានគ្រោះថ្នាក់ដោយប្រការណាមួយ ។ នាយកសាលា គប្បីសួរសំណួរដូចខាងក្រោម ដើម្បីអោយគ្រូពិភាក្សាតាមក្រុម ÷
   - តើមានសារៈសំខាន់អ្វីខ្លះចំពោះប្រអប់សង្គ្រោះបន្ទាន់ ?

     **ចម្លើយ :**

     - សិស្សអាចព្យាបាលរបួស ឬ ជំងឺរបស់គេនៅសាលារៀនបានយ៉ាងប្រសើរ

- ប្រអប់សង្គ្រោះបន្ទាន់ត្រូវបានប្រើប្រាស់សម្រាប់គោលបំណងនៃការអប់រំ ។

ប្រសិនបើគ្រូពុំបានឆ្លើយដូចសំណួរខាងលើទេ នាយកសាលា ត្រូវសួរបំផុស ដើម្បីប្រមូលគំនិតទាំងនេះ ។

**2.** នាយកសាលា ត្រូវបង្ហាញប្រអប់សង្គ្រោះបន្ទាន់ ដោយពន្យល់ថា តើមានអ្វីខ្លះនៅក្នុងនេះ ?

- សៀវភៅណែនាំអំពីការសង្គ្រោះបន្ទាន់
- ទឹកថ្នាំសម្រាប់លាងដំបៅ
- បង់រុំរបួស
- កំប្រេះ ( សម្រាប់បិទលើដំបៅ )
- បង់ស្អិត
- ម្ជុលខ្ទាស់
- ថ្នាំបិទភ្ជាប់លើដំបៅ
- កន្ត្រៃ
- ប៉ុង
- ថ្នាំសម្រាប់លាយជាមួយទឹក ( Oral Rehydration Salt )
- ក្រែមលាបការពារ ពេលសត្វទិច , ខាំ , រលាក , រោល
- ស្រោមដៃផ្លាស្ទិច ។

**<u>ចំណាំ</u>** : នៅក្នុងប្រអប់នេះ ត្រូវដាក់តែសម្ភារណាដែលតិចតួច ដែលយើងត្រូវការចាំបាច់ ។ ប្រសិនបើមានសំណូមពរពីគ្រូអោយដាក់សម្ភារសម្រាប់ព្យាបាលបន្ថែមទៀត នាយកសាលា ត្រូវសម្របសម្រួលក្នុងពេលពិភាក្សាទៅលើវត្ថុដែលយើងត្រូវការចាំបាច់ ។

**3.** នាយកសាលា គប្បីសួរគ្រូអោយពិភាក្សាជាក្រុមតូច ពីការប្រើប្រាស់សម្ភារផ្សេង ៗ នៅក្នុងប្រអប់សង្គ្រោះបន្ទាន់ ។ ក្រុមនីមួយ ៗ ត្រូវសរសេរករណីសិក្សាចំនួន ៤ ទៅ ៥ បន្ទាត់ ដោយ ២ ឬ ៣ បន្ទាត់ទាក់ទងទៅនឹងសម្ភារផ្សេង ៗ ដែលមាននៅក្នុងប្រអប់ ។ ឧទាហរណ៍ ÷

- ថ្នាំសម្រាប់បន្តក់ភ្នែក : តារា បានឡើងដើមឈើ រំពេចនោះមានកម្ទេចតូចមួយចូលភ្នែករបស់វា ។ រយៈពេល ១០ នាទី បន្ទាប់មក ភ្នែករបស់តារា នៅតែមានបញ្ហានៅក្នុងភ្នែកដដែល ។ ហេតុដូចនេះតារាបានសំរេចចិត្តទៅទីចាត់ការសាលា ដើម្បីព្យាបាលភ្នែក ។ គ្រូដែលទទួលបន្ទុកលើផ្នែកព្យាបាលបានអោយ តារា បើកភ្នែក ដោយបន្តក់ទឹកថ្នាំចូល ដើម្បីលាងសំអាតភ្នែក ។ បន្ទាប់មក ភ្នែករបស់ តារា អាចប្រព្រឹត្តទៅដូចដើមវិញ ពេលនោះ តារា បានទៅរត់លេងជាមួយមិត្តភក្តិរបស់វាដូចសព្វដង ។
- ថ្នាំសម្រាប់លាយជាមួយទឹក : ( Oral Rehydration Salt ) គ្រូថ្នាក់ទី ៣ ម្នាក់ កំពុងមានការព្រួយបារម្ភ

ចំពោះសិស្សឈ្មោះ សម្បត្តិ ពីព្រោះសិស្សនេះមានជំងឺរាគរូស ព្រមទាំងក្អួតចង្អោរទៀតផង ។ មិត្តរបស់សម្បត្តិម្នាក់បានត្រលប់ទៅផ្ទះ ដើម្បីជំរាបឳពុកម្តាយរបស់សម្បត្តិ ។ ចំណែកគ្រូបានយកទឹកស្អាតសម្រាប់ហូប ១ លីត្រ ហើយចាក់ថ្នាំ ( Oral Rehydration Salt ) ចូលក្នុងទឹក ។ គ្រូបានអោយសម្បត្តិញ៉ាំថ្នាំនោះ ពីព្រោះគាត់ខ្លាច សម្បត្តិ ប្រឈមនិងការខ្សោះជាតិទឹកក្នុងខ្លួន ។ រយៈពេល កន្លះ ម៉ោង បន្ទាប់ ម្តាយសម្បត្តិបានធ្វើដំណើរមកដល់សាលា រួចក៏នាំយកសម្បត្តិទៅកាន់មណ្ឌលសុខភាពនៅក្បែរនោះ ។ សម្បត្តិ បានទទួលនូវការព្យាបាលបានយ៉ាងត្រឹមត្រូវ ។ បន្ទាប់ពី ២ ឬ ៣ ម៉ោង សម្បត្តិ ក៏មានសុខភាពធម្មតាវិញ ។

បន្ទាប់ពីបង្ហាញករណីសិក្សានីមួយ ៗ រួច ត្រូវធ្វើការពិភាក្សាលើរបៀបប្រើប្រាស់សម្ភារក្នុងប្រអប់សង្គ្រោះបន្ទាន់អោយបានសមស្រប ។

4. នាយកសាលា ត្រូវសួរទៅគ្រូទាំងអស់ ដើម្បីពិភាក្សាជាក្រុមតូចតាមសំណួរដូចខាងក្រោម ÷

- តើយើងត្រូវរៀបចំយ៉ាងដូចម្តេច ដើម្បីធានាថា មានការប្រើប្រាស់ប្រអប់សង្គ្រោះបន្ទាន់បានល្អនៅក្នុងសាលារបស់យើង ?

**<u>ចម្លើយ</u>** :

- បុគ្គលិកដែលបង្រៀនតាមថ្នាក់ ត្រូវទទួលការបំប៉នរយៈពេលខ្លី អំពីការប្រើប្រាស់ប្រអប់សង្គ្រោះបន្ទាន់
- ប្រកាសប្រាប់សិស្សថា ក្នុងករណីដែលមានគ្រោះថ្នាក់ សិស្សអាចទទួលបាននូវការព្យាបាលជាបន្ទាន់
- ចាត់គ្រូបង្រៀនណាម្នាក់ ទទួលខុសត្រូវក្នុងការទុកដាក់ ឬ ថែរក្សាប្រអប់សង្គ្រោះបន្ទាន់ ។

ប្រសិនបើចម្លើយរបស់គ្រូពុំបានបង្ហាញជូនដូចខាងលើទេ នាយកសាលា គប្បីប្រើសំណួរបំផុសដើម្បីប្រមូលយកគំនិតទាំងនេះ ។

5. នាយកសាលា ត្រូវរៀបចំការបំប៉នស្តីពីការប្រើប្រាស់ប្រអប់សង្គ្រោះបន្ទាន់ ។ ការរៀបចំបំប៉នស្តីពីការប្រើប្រាស់ប្រអប់សង្គ្រោះបន្ទាន់ ត្រូវអញ្ជើញគិលានុបដ្ឋាក/គ្រូពេទ្យនៅតាមមណ្ឌលសុខភាព ឬ មន្ទីរពេទ្យស្រុក ដើម្បីផ្តល់ការយល់អោយបានច្បាស់ទៅលើផ្នែកនេះ ។ គិលានុបដ្ឋាក ឬ គ្រូពេទ្យ ត្រូវបង្រៀនដល់គ្រូពីបច្ចេកទេសជួយសង្គ្រោះអំពីរបៀបប្រើសម្ភារដែលមានក្នុងប្រអប់សង្គ្រោះ ។ ជាងនេះទៅទៀត គ្រូបង្រៀនត្រូវយកចិត្តទុកដាក់លើលក្ខណៈនៃរោគសញ្ញាតាមប្រភេទជំងឺនីមួយ ៗ ។ ធ្វើបែបនេះ គ្រូមានការយល់ដឹងបានច្បាស់ ហើយអាចផ្តល់ការព្យាបាល ឬ ថ្នាំ បានទាន់ពេលវេលា ។

6. នាយកសាលា ត្រូវបន្តការពន្យល់របស់ខ្លួនទៀតថា គ្រូដែលទទួលខុសត្រូវចំពោះប្រអប់នេះត្រូវរៀបចំកាលវិភាគដូចខាងក្រោម ។ នាយកសាលា ត្រូវពន្យល់ពីចំណងជើងដែលមានក្នុងកាលវិភាគនីមួយ ៗ ដល់គ្រូ ។

## ខាងក្រោមនេះ គឺជាបញ្ជីសម្រាប់កត់សំគាល់របស់បុគ្គលិកទទួលខុសត្រូវចំពោះសម្ភារដែលបានប្រើប្រាស់ ÷

| កាលបរិច្ឆេទ | ឈ្មោះមនុស្ស ដែលបានព្យាបាល | រោគសញ្ញា | ថ្នាំព្យាបាល | សម្ភារដែល បានប្រើ | បរិមាណ ដែលបានប្រើ | សកម្មភាព ជួយបន្ថែម | ហត្ថលេខា |
|---|---|---|---|---|---|---|---|
| ១០-៦-០៣ | សុខ - តារា | កំទេចតូច ៗ ចូលភ្នែក | ថ្នាំបន្តក់សម្រាប់ លាងសំអាត ភ្នែក | ទឹកលាង សំអាតភ្នែក | ១ លីត្រ | | |
| ១១-៦-០៣ | ពេជ្រ- សម្បត្តិ | ក្អួត និង រាគរូស | ថ្នាំការពារ កុំអោយខ្សោះ ជាតិទឹក | ថ្នាំសម្រាប់លាយ ជាមួយទឹក Rehydration Salt | ១ កញ្ចប់ | ម្តាយបាននាំ សម្បត្តិទៅ មណ្ឌលសុខ ភាព | |

## បញ្ជីរាយឈ្មោះសម្ភារដែលមានក្នុងប្រអប់សង្គ្រោះបន្ទាន់

| កាលបរិច្ឆេទ ពេលទទួល | សម្ភារសង្គ្រោះ បន្ទាន់ | | ថ្ងៃផុត កំណត់ | កាលបរិច្ឆេទ ថ្ងៃប្រើប្រាស់ | បរិមាណ ប្រើប្រាស់ | បរិមាណ នៅសល់ | កំណត់ សំគាល់ | ហត្ថលេខា |
|---|---|---|---|---|---|---|---|---|
| | ឈ្មោះថ្នាំ | បរិមាណ | | | | | | |
| ១០-០៣-០៣ | ថ្នាំការពារកុំ អោយខ្សោះ ជាតិទឹក | ២០ កញ្ចប់ | ៣១-១២-០៥ | ១១-០៦-០៣ | ១ កញ្ចប់ | ១៩ កញ្ចប់ | | |
| | ថ្នាំការពារកុំ អោយខ្សោះ ជាតិទឹក | ១៩ កញ្ចប់ | ៣១-១២-០៥ | ១៥-០៦-០៣ | ១ កញ្ចប់ | ១៦ កញ្ចប់ | ថ្នាំ ២ កញ្ចប់ ត្រូវបាន គេយក ដោយពុំ មានការ អនុញ្ញាត | |
| | ថ្នាំការពារកុំ អោយខ្សោះ ជាតិទឹក | ១៦ កញ្ចប់ | ៣១-១២-០៣ | ០២-០៧-០៣ | ២ កញ្ចប់ | ១៤ កញ្ចប់ | | |

| កាលបរិច្ឆេទពេលទទួល | សម្ភារសង្គ្រោះបន្ទាន់ | | ថ្ងៃផុតកំណត់ | កាលបរិច្ឆេទថ្ងៃប្រើប្រាស់ | បរិមាណប្រើប្រាស់ | បរិមាណនៅសល់ | កំណត់សំគាល់ | ហត្ថលេខា |
|---|---|---|---|---|---|---|---|---|
| | ឈ្មោះថ្នាំ | បរិមាណ | | | | | | |
| ១០-០៣-០៣ | ទឹកថ្នាំសំរាប់លាងសំអាតភ្នែក | ២ លីត្រ | ៣១-១២-០៥ | ១២-០៤-០៣ | ១ លីត្រ | ១ លីត្រ | | |
| | ទឹកថ្នាំសម្រាប់លាងសំអាតភ្នែក | ១ លីត្រ | ៣១-១២-០៣ | ២០-០៦-០៣ | ១ លីត្រ | ០ លីត្រ | សូមទិញថ្មីបន្ថែម | |
| ១៨-០៥-២០០៣ | ទឹកថ្នាំសម្រាប់លាងសំអាតភ្នែក | ៣ លីត្រ | ៣១-១២-០៤ | ២០-០៦-០៣ | ១ លីត្រ | ២ លីត្រ | | |

បុគ្គលិកដែលទទួលខុសត្រូវលើផ្នែកនេះ ត្រូវទិញថ្នាំ ឬ សម្ភារផ្សេង ៗ បន្ថែមទៀតបញ្ចូលក្នុងប្រអប់សង្គ្រោះបន្ទាន់ ។ នាយកសាលាត្រូវសួរទៅបុគ្គលិករបស់ខ្លួនក្រែងគ្មានអ្នកទទួលខុសត្រូវចំពោះប្រអប់នេះ ។ ក្នុងករណីដែលពុំមានអ្នកស្ម័គ្រចិត្តទេ នាយកត្រូវតែតែងតាំងអ្នកណាម្នាក់ ។ នាយកត្រូវពិនិត្យតាមដានទៅលើប្រអប់នេះនិងទៅលើគ្រូដែលទទួលខុសត្រូវ ។ នាយកសាលា ត្រូវពន្យល់ទៅលើគ្រូបង្រៀនទាំងអស់ថា ត្រូវតែបញ្ជាក់ប្រាប់សិស្សអោយបានយល់ច្បាស់ពីប្រអប់សង្គ្រោះបន្ទាន់នេះ ។ ក្នុងករណីដែលមានគ្រោះថ្នាក់ ឬ របួស ដោយប្រការណាមួយនោះ ពួកគេត្រូវទៅទីចាត់ការសាលា ដើម្បីទទួលការព្យាបាល ។

7. នាយកសាលា ត្រូវពន្យល់សិស្សទាំងអស់ បើសិនសិស្សទាំងអស់មានគ្រោះថ្នាក់កើតឡើង គេគួរតែផ្តល់ដំណឹងទៅលោកគ្រូ ឬ អ្នកគ្រូអោយបានលឿនបំផុត ។ ពេលនោះលោកគ្រូ-អ្នកគ្រូ ត្រូវតែជួយសិស្សដែលមានគ្រោះថ្នាក់ណាមួយនោះទៅកាន់ទីចាត់ការសាលា ដើម្បីព្យាបាល ។ នាយកសាលា ត្រូវបិទការប្រជុំ ដោយសួរថា តើមានសំណួរ ឬ សំណូមពរអ្វីទេ ?